ម៉ាស៊ីនបូមទឹកដែលខ្លាំង ហើយសាមញ្ញដែលមានលក់នៅទីផ្សារក្នុងស្រុក

គ្រួសារមួយនេះមានការរីករាយដោយសារមានឧបករណ៍សម្រាប់បូមទឹកបានយ៉ាងងាយស្រួលពីអណ្តូង។ រូបថត សហការី

Charles Amery

ទឹកគឺជាប្រភពដ៏មានតម្លៃបំផុត និងមានសារៈសំខាន់បំផុតសម្រាប់គ្រប់ទិដ្ឋភាពនៃជីវិតមនុស្ស សត្វនៅលើផែនដីយើងនេះ។

ហើយការផ្គត់ផ្គង់ទឹកនៅក្នុងរាជធានីនៃប្រទេសកម្ពុជាគឺជាជោគជ័យមិនដឹងខ្លួននៅលើឆាកអន្តរជាតិតាមរយៈរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ជាក្រុមហ៊ុនដែលគ្រប់គ្រងដោយខ្លួនឯងដំណើរការដោយពុំមានការជួយពីរដ្ឋ ការអភិវឌ្ឍគួរឲ្យកត់សម្គាល់ និងវឌ្ឍនភាព និងសមត្ថភាពគួរឲ្យកត់

សម្រាប់រាជធានីនេះធ្វើឲ្យវាក្លាយជាជ័យលាភីកាលពីឆ្នាំទៅនូវរង្វាន់ឧស្សាហកម្មទឹកទីក្រុងស្អកខមដ៏ល្បីល្បាញលើឆាកអន្តរជាតិ។

ប៉ុន្តែ ខណៈនេះមានន័យថា រាជធានីភ្នំពេញមានការផ្គត់ផ្គង់ទឹកនៅទូទាំងក្រុងពេញ ២៤ ម៉ោងសម្រាប់គ្រួសារនានារបស់វា តម្រូវការសម្រាប់ទឹកស្អាត និងងាយរកបានអាចក្លាយជាកត្តាកាន់តែសំខាន់នៃជីវិតរស់នៅប្រចាំថ្ងៃនៅតំបន់ជនបទនៃប្រទេសនេះ។

វាមានអង្គការក្រៅរដ្ឋាភិបាលជាច្រើននៅកម្ពុជាដែលការជម្នះបញ្ហាទឹក និងអនាម័យនៅតាមទីជនបទគឺជាផ្នែកមួយនៃគោលដៅរបស់ពួកគេ។ បេសកកម្ម និងកម្មវិធីដែលផ្តុំជាមួយវដ្តនៃភាពក្រីក្រ សុខភាព និងជីវជាតិអាហារ កសិកម្ម និងការអភិវឌ្ឍសហគមន៍។

អង្គការ Ideas at Work គឺជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយដែលមានវិធីសាស្ត្រផ្សេងៗ។ ពួកគេផលិតម៉ាស៊ីនបូមទឹករបស់កម្ពុជាដែលខ្លាំង និងសាមញ្ញជាមួយនឹងឧបករណ៍មានលក់នៅទីផ្សារក្នុងស្រុក។

ក្រៅពីមានដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលដទៃទៀត IaW បានពង្រីកការងាររបស់ពួកគេទៅដល់វិស័យជនបទនៃខេត្តនានាដោយបានបង្កើតខ្សែចង្វាក់ចែកចាយយ៉ាងសំខាន់ដើម្បីនាំផលិតផលរបស់ពួកគេទៅតាមភូមិនានា។

ផលិតផលដែលអាចជួយកែប្រែជីវិតរស់នៅរបស់ជនក្រីក្រ គ្រួសារជនបទ និងសហគមន៍ដែល Ideas at Work ដែលជាក្រុមហ៊ុនផលិត និងជាអង្គការក្រៅរដ្ឋាភិបាលមួយផងអះអាងថាគឺសម្រាប់បូមទឹកបានយ៉ាងងាយស្រួលក្នុងបរិមាណច្រើនពីអណ្តូង ស្រះ និងទឹកទន្លេដែលហូរយឺតៗដែលពួកគេជឿថាសំខាន់ជាងបរិមាណទឹកស្អាតសម្រាប់ពិសាដែលមានតិចតួច។

IaW ផលិត និងលក់ម៉ាស៊ីនបូមទឹកដែលដាក់ស្លាកក្រោមឈ្មោះ ROVAI ពីរោងចក្ររបស់ខ្លួននៅរាជធានីភ្នំពេញដែលគ្រប់គ្រង និងដំណើរការដោយបុគ្គលិកជនជាតិខ្មែរ ដែលពួកគេមួយចំនួនជាជនពិការដើម្បីជួយដល់ប្រជាជនរបស់ពួកគេ។

វាគឺម៉ាស៊ីនបូមទឹកទាំងនេះហើយដែលជាផលិតផលសំខាន់ក្នុងវិស័យទឹក និងអនាម័យដែលជួយប្រជាពលរដ្ឋលើវិស័យសុខភាព ឲ្យមាន

ជាងមុន ប្រព័ន្ធស្រោចស្រព ចំណាយពេលវេលាតិច និងមានសត្វ មានសុខភាពល្អជាងមុន។

ជាអង្គការក្រៅរដ្ឋាភិបាលដែលជាជ័យលាភីខ្លួនឯង Ideas at Work បានធ្វើការជាមួយអង្គការអន្តរជាតិធំៗជាច្រើនមានជាអាទិ៍ World Vision Red Cross និង PLAN International រហូតដល់មជ្ឈមណ្ឌលក្មេងកំព្រាក្នុងស្រុក និងអង្គការក្រៅរដ្ឋាភិបាលតូចធំដូចគ្នាដែលកំពុងដំណើរការនៅកម្ពុជា។

សម្រាប់ Angelique Smit ដែលបានឈានជើងមកដល់កម្ពុជាដំបូងក្នុងឆ្នាំ ២០០១ ក្នុងនាមជាឱសថការីជាមួយអង្គការ Pharmaciens sans Frontieres អង្គការ Ideas at Work ដែលនាងជាផ្នែកមួយជួយបង្កើតវានៅប្រទេសនេះបានក្លាយទៅជាអ្វីដែលនាងចូលចិត្តហៅថាជាក្រុមហ៊ុនសង្គមជាងក្រុមហ៊ុនដែលរកស៊ី។

ក្រសួងអភិវឌ្ឍជនបទបានកត់ត្រាចំនួនអណ្តូងទឹកដីច្រើនជាង ៨០ ម៉ឺនកន្លែងនៅកម្ពុជា។ អត្ថប្រយោជន៍ និងគុណសម្បត្តិនៃការបូមទឹកពីក្រោមដីមានធំធេងខ្លាំងណាស់។

សម្រាប់ទឹកដែលជាចំណុចសំខាន់មួយនៃជីវិតនៅតាមភូមិដ្ឋាន ហើយវាមានអង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលកំពុងធ្វើការនៅតាមបណ្តាភូមិ និងសហគមន៍ជនបទដែលតាមរយៈនោះម៉ាស៊ីនបូមទឹក ៨៥% ត្រូវបានលក់ដាច់ទៅដល់ប្រជាជន និងសហគមន៍ដែលត្រូវការវាខ្លាំងបំផុត។

ក្រោយដំណើរការជិត ៥ ឆ្នាំជាមួយការបង្កើត ផលិត និងបន្តកែច្នៃផលិតផល និងបង្កើតបណ្តាញចែកចាយដោយយឺតៗ ម៉ាស៊ីនបូមទឹកជាង ៣ ៥០០ គ្រឿងបច្ចុប្បន្នកំពុងដំណើរការនៅតំបន់ខេត្ត ១៩ ហើយគោលបំណង លក់ឲ្យបាន ៣ មុនគ្រឿងនៅឆ្នាំ ២០២០។

ក្រោយដំណើរការបានប៉ុន្មានខែ ទឹកបូមចេញពីអណ្តូងជាច្រើនដោយប្រើម៉ាស៊ីនទាំងនេះត្រូវបានយកមកធ្វើតេស្តជីវសាស្ត្រ និងបញ្ជាក់ថា មានបាក់តេរីតិចជាងមុន ៩០% នៅក្នុងទឹកអណ្តូងរាក់ទាំងនេះដែលមានជម្រៅ ១០ ម៉ែត្រ។

ប៉ុន្តែការទទួលបានការយល់ដឹងរបស់ពលរដ្ឋជនបទអំពីម៉ាស៊ីនបូមទឹក និងអត្ថប្រយោជន៍របស់វាទាំងនេះ ការចែកចាយវាទៅដល់អ្នកភូមិដែលត្រូវការវា និការបង្កើតតម្រូវការសំខាន់ទាំងអស់សម្រាប់បណ្តាញចែកចាយ និងការលក់ផ្ទាល់គឺជាតួនាទីកំពុងបន្តដើម្បីនាំយកផលិតផលនេះ និងផលិតផលផ្តល់ប្រយោជន៍ដល់ជីវិតដទៃទៀតនៅក្នុងថ្ងៃអនាគតឲ្យបានទៅដល់តំបន់ដែលនៅឆ្ងាយៗ។

> ប្រជាជនក្រនឹងធ្វើដំណើរណាស់ ពួកគេមានតម្រូវការតិចតួច ហើយពួកគេតែងតែយល់ថា វាពុំចាំបាច់សម្រាប់បច្ចេកវិទ្យាថ្មីដូចជាម៉ាស៊ីនបូមទឹក ព្រោះពួកគេពុំបានយល់ដឹងអំពីអត្ថប្រយោជន៍...

លោក ហ៊ុយ តារា អ្នកគ្រប់គ្រងទូទៅ IaW បានថ្លែងថា៖«ប្រជាជនក្រនឹងធ្វើដំណើរណាស់ ពួកគេមានតម្រូវការតិចតួច ហើយពួកគេតែងតែយល់ថា វាពុំចាំបាច់សម្រាប់បច្ចេកវិទ្យាថ្មីដូចជាម៉ាស៊ីនបូមទឹក ព្រោះពួកគេពុំបានយល់ដឹងអំពីអត្ថប្រយោជន៍ទាំងនោះ។ អង្គការក្រៅរដ្ឋាភិបាលឃើញប្រជាជន និងបានពន្យល់អត្ថប្រយោជន៍ និងលទ្ធភាពនៃការធ្វើឲ្យជីវភាពប្រចាំថ្ងៃមានភាពងាយស្រួលជាងមុន»។

នាង Angelique មានការស្រងាកចិត្តជាមួយអាកប្បកិរិយារបស់ចៅហ្វាយនាយជនជាតិអឺរ៉ុប និងអាមេរិករបស់នាងក្នុងតំណែងចាស់របស់នាងនៅកម្ពុជា ដោយសារនាងមានអារម្មណ៍ថា ពួកគេតែងតែបញ្ជាពីចម្ងាយដោយពុំបានដឹងអ្វីដែលកំពុងកើតឡើងនោះឡើយ។ នាងបានគូសបញ្ជាក់ថា៖«ខ្ញុំចាប់ផ្តើមស្វែងរកគំនិតផ្សេងលើរបៀបដែលយើងអាចជួយប្រជាជន។ ធ្វើឲ្យគំនិតដែលមនុស្សមានក្លាយជាការពិត។ គេម្នាក់បានលើកឡើងពីជម្រើសម៉ាស៊ីនបូមទឹក។

តាមពិត វាមិនមែនជាវិទ្យាសាស្ត្រទំនើបអ្វីទេ ដោយពឹងផ្អែកលើម៉ូដែលដែលមានអាយុ ២ ពាន់ឆ្នាំរបស់ចិន ប៉ុន្តែឧបករណ៍សម្រាប់ផលិតមានលក់នៅតាមទីផ្សារតំបន់ដែលមានន័យថា បើវាខូច វាអាចជួសជុលបានងាយស្រួលដោយអ្នកភូមិខ្លួនពួកគេ»។

នាងបានបន្តថា៖«នៅឆ្នាំ ២០០៦ យើងទទួលបានរង្វាន់អភិវឌ្ឍទីផ្សារពីធនាគារពិភពលោក ហើយពេលនោះគំនិតនេះក្លាយជាម៉ឹងម៉ាត់។ យើងមានប្រាក់សម្រាប់ធ្វើរោងចក្រ ហើយតាំងពីពេលនោះមក ម៉ាស៊ីនបូមទឹក ៣ ៥០០ គ្រឿងត្រូវបានផលិតឡើង»។

នាងបានបន្តថា៖«យើងនៅតែត្រូវការរក្សាសន្ទុះជាមួយផលិតផលនោះ ធ្វើឲ្យពលរដ្ឋដែលត្រូវការវាបានយល់ដឹងថា

លកវាផ្ទាល់ទៅដល់ប្រជាជន។

អង្គការក្រៅរដ្ឋាភិបាលដទៃទៀតផ្តល់នូវបណ្តាញចែកចាយ ប៉ុន្តែវាលែងមានទៀត នៅពេលពួកគេបញ្ចប់ការងារគម្រោងដែលពួកគេធ្វើនៅតាមខេត្ត។ យើងចង់ឲ្យមានបណ្តាញចែកចាយអចិន្ត្រៃយ៍ទៅដល់តំបន់ជនបទដោយឯករាជ្យពីយើង»។

នាងបានបន្តថា៖«យើងកំពុងប្រើម៉ាស៊ីនបូមទឹកដើម្បីរចនាបណ្តាញចែកចាយបែបនោះសម្រាប់ផលិតផលផ្សេងទៀត។ វាប្រើពេលដំបូងយូរខ្លាំងណាស់ដើម្បីលក់...ប្រើពេលយូរខ្លាំងណាស់។ យើងបានត្រឡប់ទៅបញ្ចុះបញ្ចូលពួកគេជាញឹកញាប់អំពីអត្ថប្រយោជន៍។ វាកើតឡើងយឺតៗខ្លាំងណាស់។ យើងក៏បានព្យាយាមធ្វើការជាមួយក្រុមហ៊ុនក្រេឌីតមីក្រូ ដែលមួយចំនួនមានភាពរឹងមាំនៅតាមតំបន់ជនបទ»។

នាងបានបន្តទៀតថា៖ «យើងមានបំណងដាក់ឲ្យម៉ាស៊ីនបូមទឹក ៣ ម៉ឺនគ្រឿងដំណើរការនៅឆ្នាំ ២០២០។ យើងនឹងក្លាយជាក្រុមហ៊ុនកម្ពុជាមួយដែលមានជនជាតិកម្ពុជាគ្រប់គ្រងវា ហើយវាសម្រាប់ប្រជាជនកម្ពុជា»។

អង្គការ Ideas at Work ក៏បានចុះបញ្ជីការជាមួយក្រសួងមហាផ្ទៃផលិតម៉ាស៊ីនបូមទឹក ៤ ប្រភេទ រួមមានម៉ាស៊ីនបូមទឹកសហគមន៍ សម្រាប់គ្រួសារ រហូតដល់ទៅ ២០ គ្រួសារ ម៉ាស៊ីនបូមទឹកលក្ខណៈគ្រួសារ សម្រាប់គ្រួសារដែលមានគ្នា ៣នាក់ ម៉ាស៊ីនបូមទឹកមានដៃកាន់ពីរ ភាគច្រើនសម្រាប់សាលារៀន និងក្មេងៗ មិនមែនជាម៉ាស៊ីនបូមទឹកចេញពីក្នុងស្រះទេ។

ទោះជាយ៉ាងណាវាត្រូវបានលក់ក្នុងតម្លៃទាបរហូតដល់ ៦៥ ដុល្លារដែលរាប់បញ្ចូលទាំងគម្របអណ្តូងផង។ CR ■